# មេរៀនទី៨

# អាកប្បកិរិយាទទួលខុសត្រូវប្រកបដោយសីលធម៌

## ETHICAL RESPONSIBLE BEHAVIOR

Mrs. Bun Sophany, និង គ្រូឧទ្ទេសរបស់វិទ្យាស្ថានជាតិអប់រំ

- មនុស្សជាភាវៈដែលមានវិចារញ្ញាណដែលស្គាល់ "**ត្រូវ**" និង"**ខុស**" ។



# ហេតុអ្វីមនុស្សត្រូវប្រកបដោយសីលធម៌ ?

❑

# មាតិកា

១. ហេតុអ្វីមនុស្សត្រូវប្រកបដោយសីលធម៌ ?

២.សម្ដែងរឿងខ្លី ( ROLE PLAY )

៣. សំណួរឆ្លុះបញ្ចាំង

៤. ទស្សនាវីដេអូ

៥. សកម្មភាពបញ្ជ្រាប GCED សិស្ស

តើយើងត្រូវធ្វើដូចម្ដេចដើម្បីឱ្យសិស្សក្លាយជាមនុស្សការទទួលខុសត្រូវប្រកបដោយសីលធម៌ ?

ការបញ្ជ្រាបការទទួលខុសប្រកបដោយសីលធម៌នៅក្នុងកិច្ចតែងការបង្រៀន

៦. សកម្មភាពបញ្ជ្រាប GCED ក្នុងកិច្ចតែងការ

៧. ការសន្និដ្ឋាន

- ## វត្ថុបំណងមេរៀន

១. យល់ពីភាពចាំបាច់ដែលជាពលរដ្ឋត្រូវមានទំនួលខុសត្រូវប្រកបដោយសីលធម៌ និងសទ្ធម។

២. បង្ហាញពីការបញ្ជ្រាបការទទួលខុសប្រកបដោយសីលធម៌នៅក្នុងកិច្ចតែងការបង្រៀន។

៣. ចូលរួមបណ្ដុះបណ្ដាលឥរិយាបថប្រកបដោយសីលធម៌

## ២. សម្តែងរឿង ROLE PLAYING (កណ្តុរ និងអន្ទាក់)

•កាលពីព្រេងនាយមានកណ្តុរមួយបានលួចមើលកសិករពីរនាក់ប្តីប្រពន្ធរើអីវ៉ាន់ដែលទើប តែទិញពីផ្សារក្រែងលោមានចំណីអ្វីដែលខ្លួនអាចលួចស៊ីបាន។ កណ្តុរមានការតក់ស្លុតយ៉ាងខ្លាំងនៅពេលដែលវាបានឃើញអន្ទាក់សម្រាប់ ដាក់វាទៅវិញ។ កណ្តុរបានរត់ចេញទៅខាងក្រៅផ្ទះហើយបានស្រែកប្រកាសអាសន្នថា «មានអន្ទាក់កណ្តុរនៅក្នុងផ្ទះ!»។ មេមាន់ដែលឮសម្រែករបស់កណ្តុរមុនគេបានងក់ក្បាលតិចៗហើយនិយាយទៅ កាន់កណ្តុរថា «សម្លាញ់!ខ្ញុំយល់ថាសម្លាញ់ពិតជាមានការតក់ស្លុតយ៉ាងខ្លាំងនៅពេល បានឃើញអន្ទាក់សម្រាប់ដាក់ខ្លួនឯងយ៉ាងដូច្នេះ តែអន្ទាក់នោះមិនមែនសម្រាប់ដាក់គ្នាទេដូច្នេះគ្នាគ្មានអ្វីត្រូវ បារម្ភឡើយ។ សូមសម្លាញ់ប្រយ័ត្នប្រយែងណា!»។ ដោយអារម្មណ៍ភ័យខ្លាចកណ្តុរក៏បានទៅជួបជ្រូក។ ជ្រូកអាណិតអាសូរកណ្តុរយ៉ាងខ្លាំងហើយបាននិយាយថា «សម្លាញ់គ្នាមិនអាចជួយអ្វីដល់ឯងបានក្រៅតែពីការបួងសួងសុំមឲ្យ សម្លាញ់បានសេចក្តីសុខរួចពីអន្ទាក់នោះ»។

•កណ្តុរបន្តដំណើររបស់ខ្លួនហើយក៏ទៅប្រាប់គោៗបានឆ្លើយយ៉ាង ព្រងើយដាក់កណ្តុរវិញថា «អន្ទាក់តូចណាស់សម្រាប់ដាក់តែឯងតែប៉ុណ្ណោះមិនមែនសម្រាប់ដាក់គ្នា ទេ ថែរក្សាខ្លួនសម្លាញ់»។

•កណ្តុរបានត្រឡប់មករកមើលថាតើអន្ទាក់នោះដាក់នៅកន្លែងណាទាំង ការភិតភ័យ និងអស់សង្ឃឹមតែម្នាក់ឯងដេកនៅក្នុងរន្ធរបស់ខ្លួនចាំស្តាប់ សភាពការណ៍។ នៅយប់នោះមានសំឡេងឮដូចជាសំឡេងអន្ទាក់ដែលវាត់ជាប់សត្វអ្វីមួយ។ ប្រពន្ធកសិករបានប្រញាប់ទៅពិនិត្យក្រែងលោអន្ទាក់របស់ខ្លួនចាប់ បានកណ្តុរ។ដោយយប់ងងឹតគាត់មិនបានឃើញពស់ជាប់អន្ទាក់នោះទេ។ ពស់ក៏បានចឹកគាត់ហើយពិសពស់បានធ្វើឲ្យគាត់មានអាការក្តៅខ្លួន យ៉ាងខ្លាំង។អ្នកភូមិប្រាប់គាត់ថាស៊ុបមាន់ក្តៅៗអាចជួយឲ្យអ្នកមានអាការក្តៅខ្លួនដោយសារពស់ចឹក ធូរស្រាលបាន។

•កសិករនោះក៏បានសម្លាប់មាន់ដើម្បីធ្វើស៊ុបឲ្យប្រពន្ធគាត់ហូប ប៉ុន្តែជំងឺមិនបានធូរស្រាលនោះទេ។ មិត្តភក្តិ និងអ្នកជិតខាងរបស់គាត់បានមកសួរសុខទុក្ខជាហូរហែ។ ដោយសារគាត់គ្មានអ្វីទទួលភ្ញៀវ គាត់ក៏បានសម្លាប់ជ្រូកដើម្បីធ្វើម្ហូបទទួលទាន។ប៉ុន្មានសប្តាហ៍ ក្រោយមកទៀតប្រពន្ធរបស់គាត់ក៏ស្លាប់។ កសិករបានឲ្យគេសម្លាប់គោធ្វើម្ហូបទទួលភ្ញៀវនៅក្នុងពិធីបុណ្យសព នោះទៅ។ ដោយសារការភ័យខ្លាចកណ្តុរដែលមិនអាចធ្វើអ្វីបាន ក៏បន្តសម្ងំនៅក្នុងរន្ធរហូតដល់ស្លាប់តាមមិត្តភក្តិរបស់ខ្លួនអស់ទៅ។

*ដកស្រង់ចេញពីកាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃព្រហស្បតិ៍ ទី១៨ ខែមិថុនា ឆ្នាំ២០១៥*

# ៣. សំណួរឆ្លុះបញ្ចាំង (Reflection)

១. តើហេតុអ្វីបានជាកណ្ដុរយកបញ្ហារបស់ខ្លួនទៅឱ្យគេជួយដោះស្រាយ?

២. តើការស្លាប់របស់មាន់ ជ្រូក គោ បណ្ដាលមកពីអ្វី?

៣. នៅពេលអ្នកឃើញនរណាម្នាក់ត្រូវគេរំលោភសិទ្ធិជាមូលដ្ឋានតើអ្នកគួរជួយឬទេ? ហេតុអ្វី?

៤. បើអ្នកជាតួអង្គសត្វកណ្ដុរវិញ តើអ្នកធ្វើដូចម្ដេច?

៥. តើសាច់រឿងនេះ ឆ្លុះបញ្ចាំងពីសង្គមខ្មែរដែរឬទេ? ហេតុអ្វី?

៦. តើរឿងនេះ ផ្ដល់តម្លៃអប់រំអ្វីខ្លះ?

៧. តើអ្នកមានអ្វីកែលម្អក្នុងរឿងនេះ?



## ៤. ទស្សនាវីដេអូ (VEDIO)

# រឿងកាបូបលុយ

# (បន្ទាប់មានសំណួរ Reflection)



## សំណួរឆ្លុះបញ្ចាំង (Reflection)

តើចំណុចណាខ្លះក្នុងសាច់រឿងបានបង្ហាញអាកប្បកិរិយាទទួលខុសត្រូវប្រកបដោយសីលធម៌របស់តួអង្គក្មេងស្រី និងលោកវេជ្ជបណ្ឌិតក្នុងការបញ្ជ្រាបខ្លឹមសារនៃការអប់រំពលរដ្ឋសកល?

# តើភាពជាពលរដ្ឋសកលមានលក្ខណៈដូចម្តេច?

**ភាពជាពលរដ្ឋសកល**
(Oxfam GB, 2015)

- គោរព និងផ្តល់តម្លៃនូវភាពចម្រុះ
- ប្តេជ្ញាចិត្តយ៉ាងមុតមាំដើម្បីយុត្តិធម៌សង្គម
- មានការយល់ដឹងអំពីពិភពលោកធ្វើការ
- ទទួលខុសត្រូវលើអំពើរបស់ខ្លួន
- យល់ដឹងអំពីពិភពលោកកាន់តែទូលំទូលាយនិងមានអារម្មណ៍ថាតួនាទីរបស់ពួកគេម្នាក់ៗ គឺជាពលរដ្ឋសកល
- ធ្វើការជាមួយអ្នកដទៃដើម្បីធ្វើឱ្យពិភពលោកមានសមធម៌ និងជាកន្លែងដែលមានចីរភាព
- ចូលរួមនៅក្នុងសហគមន៍គ្រប់កម្រិតតាំងពីកម្រិតតំបន់រហូតដល់កម្រិតពិភពលោក

# វិស័យទាំងបីនៃការអប់រំពលរដ្ឋសកល និងលទ្ធផលសិក្សា

## Domains of Learning

### ពុទ្ធិ
### Cognitive

- អ្នកសិក្សាទទួលបានចំណេះដឹង និងយល់ដឹងអំពីបញ្ហាក្នុងតំបន់ និងពិភពលោក និងអន្តរទំនាក់ទំនង អន្តរឯករាជ្យនៃប្រទេស និងប្រជាពលរដ្ឋផ្សេងៗគ្នា។
- អ្នកសិក្សាអភិវឌ្ឍការគិត និងវិភាគស៊ីជម្រៅ



### ឥរិយាបថ
### Behavioral

- អ្នកសិក្សាធ្វើសកម្មភាពប្រកបដោយប្រសិទ្ធភាព និងទំនួលខុសត្រូវ ក្នុងកម្រិតតំបន់ និងពិភពលោកដើម្បីពិភពលោកពេញដោយសន្តិភាព និងចីរភាព។
- អ្នកសិក្សាអភិវឌ្ឍនវានុវត្ត និងឆន្ទៈដើម្បីធ្វើសកម្មភាពដែលចាំបាច់។

### ចិត្តសង្គម
### Social emotional

-អ្នកសិក្សាទទួលបានបទពិសោធន៍នៃការអារម្មណ៍ជាកម្មសិទ្ធិចំពោះមនុស្សជាតិទាំងមូល ចែករំលែកតម្លៃ និងការទទួលខុសត្រូវផ្អែកលើសិទ្ធិមនុស្ស។
- អ្នកសិក្សាអភិវឌ្ឍអាកប្បកិរិយានៃភាពអាណិតស្រលាញ់ សាមគ្គីភាព និងគោរពចំពោះពិពិតភាព និង ភាពផ្សេងៗគ្នា។
-

# ពិភាក្សាក្រុម (Group Discussion)

១. ចូរបង្ហាញអំពីវិធីបញ្ជ្រាបខ្លឹមសារនៃការអប់រំពលរដ្ឋសកល(ការទទួលខុសត្រូវប្រកបដោយសីលធម៌) ទៅក្នុងកិច្ចតែងការបង្រៀនរបស់អ្នក។



# ៥. ការបញ្ជ្រាបGCED នៅដល់គរុសិស្ស





# គរុនិស្សិតបញ្ជ្រាប GCED នៅវិទ្យាល័យក្នុងពេលកម្មសិក្សា

Learning by doing ( John Dewey )



គរុស្សិតជំនាញសីលធម៌ពលរដ្ឋ បង្រៀនសិស្សនៅវិទ្យាល័យ។



## យល់ពីភាពចាំបាច់ដែលជាពលរដ្ឋត្រូវមានទំនួលខុសត្រូវប្រកបដោយសីលធម៌ និងសង្គម

- បុគ្គលម្នាក់ៗក្នុងនាមជាសមាជិករបស់ពិភពលោកត្រូវទទួលខុសត្រូវចំពោះខ្លួនឯង គ្រួសាររបស់ខ្លួន សហគមន៍ដែលខ្លួនរស់នៅ និងពិភពលោក ។
- ដើម្បីឱ្យមានការទទួលខុសត្រូវនឹងប្រកបដោយសីលធម៌ត្រូវបណ្តុះពីក្នុងថ្នាក់ ជាថ្នាក់រៀនបែបប្រជាធិបតេយ្យ (DEWEY)។

CONSTRUCTIVISM (PBL, IBL, CBL…)







## តើយើងត្រូវធ្វើដូចម្ដេចដើម្បីឱ្យសិស្សក្លាយជាមនុស្សមានការទទួលខុសត្រូវប្រកបដោយសីលធម៌ ?

- សិស្សអាចរៀនបានជាច្រើនទៀតអំពីអាកប្បកិរិយាសីលធម៌នៅពេលចូលរួមក្នុងការដោះស្រាយបញ្ហា ដែលពួកគេជួបប្រទះនៅក្នុងថ្នាក់ឬនៅពេលមានការដាក់កិច្ចការឱ្យ ។
- បញ្ជ្រាបលើបីចំណុច៖ ចំណេះដឹង ចិត្តសង្គម និង

អាកប្បកិរិយា ។

- ហេតុនេះ វាមិនត្រឹមតែ ជាចំណេះដឹងទេ ប៉ុន្តែត្រូវជាចំណេះដឹង ដែលប្រតិបត្តិ ក្នុងសហគមន៍។



## តើយើងត្រូវធ្វើដូចម្តេចដើម្បីឱ្យសិស្សក្លាយជាមនុស្សមានការទទួលខុសត្រូវប្រកបដោយសីលធម៌ ?

ធ្វើឱ្យសិស្សមានអារម្មណ៍ថា ជាកម្មសិទ្ធិនៃមនុស្សលោក ចែករំលែកតម្លៃ និងការទទួលខុសត្រូវ ផ្អែកលើសិទ្ធិមនុស្ស ។

- ឱ្យពួកគេធ្វើសកម្មភាពប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវទៅតាមកម្រិតតំបន់ ថ្នាក់ជាតិ និងសកលលោកដោយសន្តិភាព និងចិរភាព ។

- ការបង្រៀន ត្រូវតែធ្វើឱ្យមានការ ប្រែប្រួល នៅក្នុងសហគមន៍ ជាវិជ្ជមាន។





# ការបញ្ជ្រាបGCED ក្នុងកិច្ចតែងការបង្រៀន

# ពិភាក្សាក្រុម (Group Discussion)

១.  ចូរបង្ហាញអំពីវិធីបញ្ជ្រាបខ្លឹមសារនៃការអប់រំពលរដ្ឋសកល(ការទទួលខុសត្រូវប្រកបដោយសីលធម៌)  ទៅក្នុងកិច្ចតែងការបង្រៀនរបស់អ្នក។



# ដំណាក់កាលនៃគំរូ E5

## Engage
ចូលរួមក្នុងស្ថានភាពនៃបញ្ហា គាស់ចំណេះដឹងចាស់ ធ្វើឱ្យសិស្សឆ្ងល់

- ការបំភ្លឺ (Demonstration)
- ការអាន (Reading)
- សរសេរដោយសេរី (Free Write)
- វិភាគក្រាហ្វិក (Analyze a Graphic)
- អ្នករៀបចំ (Organizer)
- បំផុសគំនិត (Brainstorming)

## Explore
សិស្សរុករកបាតុភូតប្រឈមនឹងចំណេះដឹងពីមុនមក បន្ទាប់មកលេចចេញគំនិតថ្មី

- អនុវត្តការស៊ើបអង្កេត (Perform an Investigation)
- អានប្រភពត្រឹមត្រូវដើម្បីប្រមូលព័ត៌មាន (Read Authentic Resources to Collect Information)
- ដោះស្រាយបញ្ហា (Solve a Problem)
- បង្កើតគំរូ (Construct a Model)

## Explain
សិស្សពន្យល់បាតុភូត បង្ហាញរបកគំហើញថ្មី ឬចំណេះដឹងថ្មីត្រូវបានបង្ហាញ

- សិស្សវិភាគ និងការពន្យល់
- គាំទ្រគំនិតជាមួយនឹងភស្តុតាង
- សំណួររៀបជា/សួរជារចនាសម្ព័ន្ធ
- អាន និងពិភាក្សា
- ការពន្យល់របស់គ្រូ
- សកម្មភាពជំនាញនៃការគិត៖ ប្រៀបធៀប, ចាត់ថ្នាក់, វិភាគកំហុស

## Elaborate
សិស្សអនុវត្តចំណេះដឹងថ្មីជាមួយស្ថានភាពថ្មី ដែលកាន់តែជ្រៅ និងទូលំទូលាយ

- ដោះស្រាយបញ្ហា (Problem Solving)
- ការធ្វើសេចក្ដីសម្រេច (Decision Making)
- ការសាកសួរពិគ្រោះ (Experimental Inquiry)
- ជំនាញការគិត (Thinking Skill)
- សកម្មភាព៖ ប្រៀបធៀប, ចាត់ថ្នាក់, អនុវត្ត

## Evaluate
សិស្សឆ្លុះបញ្ចាំងចំណេះដឹង ដំណើរការនៃការរៀន និងការវាយតម្លៃ។

- សកម្មភាពណាមួយដែលធ្វើពីមុន
- អភិវឌ្ឍឧបករណ៍ដាក់ពិន្ទុ ឬជំពូក
- វាយតម្លៃការអនុវត្ត
- ផលិតឱ្យទៅជាផលិតផល
- ធាតុទិនានុប្បវត្តិ
- ផលប័ត្រ (Portfolio)

| ជំហានទី៣ (“មេរៀនប្រចាំថ្ងៃ” ៣០នាទី)<br>មេរៀនទី៧៖ចំណោទបញ្ហាក្នុងសហគមន៍ និងដំណោះស្រាយ | | |
|---|---|---|
| **១. ចូលរួម** (Engage ស្តាប់ អង្កេត ប្រៀបធៀបបទពិសោធន៍ចាស់ និងថ្មី)<br>ដើម្បីទាក់ទាញចំណាប់អារម្មណ៍ គ្រូអាចសួរសំណួរខាងក្រោម៖<br>១. តើភូមិរបស់ប្អូនមានទឹកស្អាតប្រើប្រាស់ឬនៅ? ហេតុអ្វី?<br>គ្រូបង្ហាញរូបភាពរួចសួរបន្តដឹកចំណេះដឹងរបស់គេស្តីអំពីសហគមន៍។<br>២. ចូរប្អូនមើលរូបភាពនេះ មានចំណាប់អារម្មណ៍អ្វីខ្លះ? សិស្សមើលរូបភាព និងបង្ហាញនូវអ្វីដែលពួកគេបានឃើញ។<br> | ១. បាទ/ ចាស ២. ទេ<br>មូលហេតុទៅតាមសិស្សតំបន់ដែលគេរស់នៅ។<br>២. ក្មេងៗទៅសាលារៀន ការតវ៉ារបស់សហគមន៍រងគ្រោះ ខ្វះអនាម័យ និងទឹកស្អាត ជម្លោះដីធ្លី បញ្ហាសុខភាពនៅក្នុងសហគន៍ ការកាប់បំផ្លាញព្រៃឈើ បញ្ហាប្រឈមរបស់កុមារក្រីក្រក្នុងសហគមន៍ជួបការលំបាក។ | សិស្សស្តាប់ និងឆ្លើយសំណួរ<br>១. បាទ/ចាស/ទេ<br>សិស្សរៀបរាប់អំពីមូលហេតុរបស់ពួកគេ។<br>សិស្សមើលរូបភាព និងឆ្លើយសំណួររបស់គ្រូនូវអ្វីដែលគេយល់ឃើញ។<br>២. ក្មេងៗទៅសាលារៀន ការតវ៉ារបស់សហគមន៍រងគ្រោះ ខ្វះអនាម័យ និងទឹកស្អាត ជម្លោះដីធ្លី បញ្ហាសុខភាពនៅក្នុងសហគន៍ ការកាប់បំផ្លាញព្រៃឈើ ការបារម្ភអនាគតយុវជន បញ្ហាប្រឈមរបស់កុមារក្រីក្រក្នុងសហគមន៍ជួបការលំបាក។ |

| | | |
|---|---|---|
| ២. រុករក (Explore)<br>ចែកសិស្សជា៤ក្រុម (ស្វែងរកចម្លើយលើសំណួរដូចគ្នា)៖<br>តើសហគមន៍របស់អ្នកមានបញ្ហាប្រឈមអ្វីខ្លះ? តើអ្នកមានដំណោះស្រាយដូចម្ដេច?<br>-ឲ្យសិស្សឆ្លុះបញ្ចាំងថ្មី គោលការណ៍ | បញ្ហាប្រឈម<br>ក. ការបំផ្លាញធនធានធម្មជាតិ<br>ខ. ការបំពុលទឹក និងខ្យល់អាកាស<br>គ. សំរាម និង កាកសំណល់<br>ឃ. ការប្រើប្រាស់ដីធ្លីខុសបច្ចេកទេស<br>ង. អសន្តិសុខសង្គម | -ប្រមូលព័ត៌មាន និងចែករំលែកគំនិត<br>-កត់ត្រាចំណុចសំខាន់ដែលពួកគេបានរកឃើញ ជាក្រុម ឬបុគ្គល។<br>-ពិភាក្សាលើអ្វីដែលពួកគេបានរកឃើញ។ |

| ជំហានទី៥ (០៥ នាទី) បណ្ដាំផ្ញើ (កិច្ចការផ្ទះ) | | |
|---|---|---|
| • គ្រូដាក់កិច្ចការផ្ទះធ្វើជាក្រុម ចូរប្អូនយកបញ្ហាប្រឈមជាក់ស្ដែង ដែលបានពិភាក្សាស្វែងរកដំណោះស្រាយនេះ ទៅអនុវត្តជាក់ស្ដែង។ | អនុវត្តគម្រោងក្នុងសហមន៍ជាក់ស្ដែង។ | សិស្សកត់ត្រាគម្រោងរបស់ក្រុមទៅអនុវត្តជាក់ស្ដែងនៅក្នុងសហគមន៍។ |




ការគំរាមកំហែងសិទ្ធិរបស់នរណា
ម្នាក់គឺស្មើនឹងការគំរាមហែងចំពោះ
មនុស្សជាតិទាំងមូល។

## ហេតុអ្វីមនុស្សត្រូវប្រកបដោយសីលធម៌ ?

Why we should be moral?

- **បញ្ជារបស់ព្រះ**
  Divine Command
- **ផលប្រយោជន៍ផ្ទាល់ខ្លួន**
  Self Interest
- **ផលប្រយោជន៍**
  Common Interest
- **ពីព្រោះភាពត្រឹមត្រូវរបស់អំពើ**
  Because Its right

## ៨. សន្និដ្ឋាន

- យើងរស់នៅលើផែនដីនេះ ត្រូវមានការទទួលខុសត្រូវទាំងសង្គម សេដ្ឋកិច្ច និងបរិស្ថាន ដើម្បីជាប្រយោជន៍សម្រាប់ជំនាន់ក្រោយ ។
- គ្រូបង្រៀនគ្រូបង្រៀនត្រូវឱ្យសិស្សចូលរួមសកម្មភាពរៀនក្នុងថ្នាក់យ៉ាងសកម្ម និងសិស្ស ជ្រើសរើសគម្រោងប្រតិបត្តិនៅក្នុងសហគមន៍។



# ៨. គន្ថនិទ្ទេស

## ក. ឯកសារជាភាសាខ្មែរ


- ក្រសួងអប់រំ យុវជន និងកីឡា. (២០១៧). សៀវភៅសិក្សាគោល សីលធម៌ពលរដ្ឋវិជ្ជាថ្នាក់ទី១២. ភ្នំពេញ


## ខ. ឯកសារជាភាសាអង់គ្លេស


- DocJonathan P. Latimer (2000). The American Heritage® Dictionary of the English Language, 3th edit. USA.
- Oxfam GB (2015). **Education for Global Citizenship**: A guide for schools.
- UNESCO (2015). **Global Citizenship Education: Topics and Learning Objectives**.
- Schools for future youth (2014). **Global Citizenship Education Framework**.
- Oxfam GB (2015). **Global Citizenship in the classroom: A guide for teachers.**
- A PMB (2007). **Active Learning and Teaching Methods for Key Stage 3.**

Crebert, G., Patrick, C.-J., Cragnolini, V., Smith, C., Worsfold, K., & Webb, F. (2011). **Ethical Behavior and Social Responsibility Toolkit**. 2nd Edition. Griffith University. (Retrieved from the World Wide Web 4th April, 2011). - http://www.griffith.edu.au/gihe/resources-support/